ស្លាបព្រាបុរាណពណ៌ស្ពាន់ នៅកម្រើកលើកម្រាលឥដ្ឋ ក្បែរជើងគាត់នៅឡើយ ហាក់ប្រាប់ថាមុននេះអ្វីមួយ បានធ្វើឱ្យគាត់ភ្ញាក់រហូតរបូតវាធ្លាក់មកលើឥដ្ឋ?

«អ្នកបម្រើម្នាក់នេះមិនមែនភ្ញាក់ផ្អើលព្រោះឮថាខ្ញុំនឹងចេញចូលផ្ទះនេះច្រើនខែទេដឹង?»

នាងធ្វើមុខស្មើសម្លឹងគាត់ ព្រមជាមួយសម្គាល់ឃើញកន្ទុយភ្នែកគាត់ដែលលបលួចមើលមកខ្លួនដោយអាថ៌កំបាំងផង។

នាងឱនបរិភោគអាហារថ្នមៗជាកិច្ចគួរសម តបតនឹងការជូលឱ្យរបស់ម្តាយមីងសាច់ថ្លៃ។ ត្រចៀកនិងភ្នែករង់ចាំជៀងពិនិត្យកាយវិការជុំវិញខ្លួនជានិច្ចក្នុងពេលដំណាលគ្នា។

ស្ត្រីដែលទើបនឹងមកដល់រៀបចំស្លាបព្រាស្ពាន់ សម្រាប់សម្ល បន្ថែមសម្រាប់ម្នាក់ៗ ពីលើស្លាបព្រាសមធម្មតាដែលបានត្រៀមលើតុមុននេះ។ ដោយសារគាត់ធ្វើជ្រុះមួយទៅហើយគាត់អាចមានតែស្លាបព្រាស្ពាន់ពីរសម្រាប់ដាក់ជូនជំទាវទាំងទ្វេមុន ចំណែករបស់ធីតាគាត់នៅជំពាក់។

សំឡេងជំទាវវត្តីបញ្ជាះ

«មៀច! នេះអ្នកនាងធីតាជាក្មួយស្រីបង្កើតរបស់ស្វាមីខ្ញុំ! គាត់មកស្នាក់នៅលេងជាមួយខ្ញុំ! ត្រូវទុកគាត់ដូចខ្ញុំដែរ! គាត់ចង់បានអីត្រូវរកជូនគាត់ឱ្យបានល្អ!»

កញ្ញាជាភ្ញៀវហាក់បានចិត្តពើងទ្រូងបន្តិចដែរពេលឮបញ្ជានេះ តែនាងខំរក្សាកាយវិកាដដែល ស្របពេលស្ត្រីឈ្មោះមៀច ហាក់ឱនគោរពតិចតួច រួចរូតរះចាកចេញទៅ សូម្បីវាចាបន្តិចក៏គ្មាន ។

«គដឹង?»

ធីតាសួរខ្លួនឯងយ៉ាងរហ័ស។

«គាត់មិនចង់គោរពខ្ញុំក៏មិនអី ព្រោះគោលដៅខ្ញុំមិនមែនរឿងពួកគាត់ទេ!»

នាងបន្តគិតម្នាក់ឯងដោយរក្សាទឹកមុខធម្មតា។

«ធីតាគេងនៅឯណា?»

ជំទាវងាកសួរកូនប្រសាស្រី ធ្វើឱ្យជំទាវតូចចរិយាដែលហាក់កំពុងស្លុងទៅក្នុងរឿងអ្វីមួយងើបមុខមកវិញមីងម៉ាំង។ សូម្បីសំណួរម្តាយក្មេកខ្លួនក៏ចរិយាចាប់មិនបានផង  បងថ្លៃម្នាក់នេះហាក់មិនមានអារម្មណ៍នៅនឹងតុបាយនេះទេ។

ធីតាដឹងថាគាត់បានជួបរឿងជាច្រើនដែលស្មុគស្មាញនិងអស់សង្ឃឹមផង។ ប្ដីបាត់ខ្លួនបីបួនខែហើយគ្មានដំណឹងមិនដឹងជាទៅណាមកណា រីឯក្នុងផ្ទះឪពុកក្មេកទើបនឹងស្លាប់ទៀត មិនឱ្យគ្មានរវើរវាយចិត្តឯណាបាន?

គិតហើយនាងក៏ផ្ដើមឆ្លើយជំនួសភ្លាម៖

«ក្មួយស្នាក់ក្នុងបន្ទប់រំចេក អ្នកមីង!»

ជំទាវស្រស់ស្អាត វេភ្នែកចេញចោលកូនប្រសាដែលនៅស្លុបមុខជាមួយស្លាបព្រាទើរក្បែរមាត់ ដូចទទួលទានខ្លះដូចអត់ខ្លះ។

គាត់ញញឹមមករកអ្នកដែលឆ្លើយជំនួសហើយ វាចាប្រាប់ទាំងលើកម្រាមទន់ស្រឡូនមកគោះកដៃនាងដោយស្និទ្ធស្នាល៖

«ចង់បានអីថែមត្រូវប្រាប់! ត្រូវទុកកន្លែងនេះជាផ្ទះរបស់ខ្លួនឯង កុំក្រែងចិត្ត!»

ជំទាវចរិយានៅតែឈ្ងោកបរិភោគស្ងប់ស្ងាត់។ ការមិននិយាយស្ដីនេះ ធ្វើឱ្យធីតាគិតស្ងាត់ៗម្នាក់ឯងថា ការបង្ខំរស់នៅក្នុងស្ថានភាពមួយដែលគ្រប់គ្នាពិបាកហាមាត់និយាយ មុខតែនាំទៅដល់ជំងឺស្ត្រេសមិនធ្ងន់ធ្ងរនៅថ្ងៃណាមួយ ដល់ពេលនោះកុំថាឡើយស្វែងរកឃាតក សូម្បីតែរក្សាសុខភាពខ្លួនក៏ពិបាកផង។

នាងតាំងចិត្តហាមាត់និយាយត្រង់ៗ៖

«ជំទាវមីង! ក្មួយចង់សុំសោចូលទៅបន្ទប់ដែលហាមឃាត់!»

ជំទាវវត្ដីមិនបានអាក់អ្វីនឹងសំណើរនេះដូចដែលធីតាគិតទុកតឹងតែងចិត្តម្នាក់ឯងទេ។ គាត់បន្តបរិភោគធម្មតា ដោយទំពាអាហារមួយៗរួចរាល់ទើបសួរបក៖

«បន្ទប់ហាមឃាត់ណាទៅ?»

ធីតាត្រូវភាំងបន្តិចវិញ នាងធ្វើភ្នែកឡិងឡង់សម្លឹងហួសទៅរកជំទាវចរិយា ធ្វើឱ្យកូនប្រសាមិនអាចធ្វើស្ងប់ស្ងាត់បន្តបានក៏ផ្ដើមនិយាយពន្យល់ម្ដាយក្មេក៖

«ពេលមកដល់ធីតាចង់មើលកន្លែងប៉ាធ្លាក់! តែកូនប្រាប់ថាសោបន្ទប់នៅនឹងអ្នកម៉ាក់!»

ជំទាវវត្ដីទម្លាក់ភ្នែកក្រៀមស្រពោនតែគាត់មិនមានប្រតិកម្មអ្វីខ្លាំងទេ។ គាត់និយាយតបមួយៗដោយទឹកមុខស្មើ៖

«បាយរួច ចាំមីងយកសោឱ្យ!»

ធីតាស្កប់ចិត្តជាងមុន។ អ្វីៗធូរស្រាលជាងដែលនាងបានគិត ដូច្នេះហើយនាងចាប់ផ្ដើមញញឹមដឹងគុណ និងបន្តបរិភោគដោយរីករាយ។

## ជំពូកទី៩

## បុរសអ្នកនាំផ្លូវ

ស្នូរជើងមនុស្សលាន់មកក្បែរតុសាឡុងដែលនាងកំពុងអង្គុយអានសៀវភៅ។

នេះជាបន្ទប់បណ្ណាល័យដែលពេញពាសទៅដោយសៀវភៅគ្រប់ប្រភេទ និងមានតម្លៃ ប្រមូលមកពីជុំវិញពិភពលោក។ មិនបាច់ឆ្ងល់ទេ គឺលោកពូខ្លួនចង់ទាក់ទាញកូនប្រុសឱ្យឧស្សាហ៍មកស្នាក់នៅកំដរគាត់បានជាគាត់បង្កើតបណ្ណាល័យដ៏ស្អាតប្រណីតនេះឡើងមក។

បងប្រុសជីដូនមួយ ធ្លាប់ជាមនុស្សម្នាក់ដែលវក់ចិត្តចំពោះបណ្ដាសៀវភៅល្បីៗនានាលើលោក។ គេមិនសូវអានច្រើនទេតែគេចូលចិត្តទិញមកជាកម្មសិទ្ធិ។

«បងឧត្តម! ឆាប់មកផ្ទះវិញ!»

នាងថាផងលើដៃសំពះបួងសួងរំងាប់ចិត្តស្រងេះស្រងោច។

បន្ទប់ដែលមានរាងជាចតុកោណ មិនធំជាង២០ម៉ែត្រការ៉េ បែរជាចោមព័ទ្ធទៅដោយទូសៀវភៅទាំងបួនទិសកសាងឡើងអំពីប្រភេទឈើនាងនួនក្រាស់ ខ្មៅរលើបនិងស្អាតវិចិត្រ។ អង្គុយនៅទីនេះមានអារម្មណ៍ដូចជារាជវាំងអាណាចក្រសម័យដ៏រុងរឿងនិងសានត្រាន្ត។ ប្រសិនមិនមានមរណភាពលោកពូនិងការបាត់ខ្លួននៃបងប្រុស កុំអីទីនេះគឺជាស្ថានសួគ៌នៃវិស្សមកាលរបស់ធីតា។

«អ្នកនាង លោកជំទាវឱ្យខ្ញុំបើកទ្វារបន្ទប់ធំជូនរួចហើយ!»

នាងងើបមុខសម្លឹងបុរសធាត់កន្ទុក។ ជននេះជាអ្នកបើកបរជូនអ្នកមីងថ្លៃ ក៏ទំនងជាមនុស្សគាត់ទុកចិត្តខ្លាំងទេដឹង ដែលមិនឱ្យសោទៅអ្នកណាបែរជាឱ្យសោទៅជននេះបើកបន្ទប់ដែលគាត់ធ្លាប់បានសម្រេចចិត្តចាក់សោចោលម្ដងរួចមកហើយនោះ?

«អរគុណ!»

នាងដាក់សៀវភៅចោលទៅក្បែរកូនពែងកាហ្វេ ហើយមិនរង់ចាំច្រើន ធីតាក្រោកដើរពីមុខការគំនាប់របស់អ្នកបើកបរ។

«អនុញ្ញាតឱ្យខ្ញុំនាំផ្លូវទាន!»

«នៅហ្នឹងសិន! ខ្ញុំទៅយកអីវ៉ាន់!»

នាងចាកចេញយ៉ាងញាប់មករកបន្ទប់ខ្លួនវិញ ទាំងចិត្តនៅនឹកគិតអំពីមនុស្សនេះ។ ធម្មតាឈ្មោះជឿននេះ និយាយស្ដីគួរសម ចេះឱនលំទោនណាស់ តែបើពិនិត្យផ្ទៀងលើសម្ដីសម្ដៅមិនសមថា គេមានចំណេះដឹងតិចតួចដូចអ្នកបើកឡានធម្មតាៗនោះទេ។

«ឬមួយជំទាវមីងប្រើគេនេះមកតាមឃ្លាំសកម្មភាពខ្ញុំ?!»

នាងគិតដោយស្វ័យប្រវត្តិ តែមាត់មិននិយាយអ្វី រួចបង្អង់ជើងចូលក្នុងបន្ទប់គេងទុកឱ្យបុរសរូបរាងធាត់ឈរចាំក្នុងសួន។

អ្វីដែលធីតាកាន់មកតាមគឺ ម៉ាស៊ីនថតរូបរបស់ពូនាងជាវត្ថុអំណោយចុងក្រោយ។

បុរសដែលមកធ្វើជាអ្នកនាំផ្លូវរេភ្នែកសម្លឹងម៉ាស៊ីនថតក្នុងដៃនាងដែរ តែធីតាធ្វើមិនដឹង។

«តោះ!»

នាងនិយាយខ្លីៗ ធ្វើឱ្យជននោះចាកចេញយឺតៗនាំពីមុខនាងទៅ។

ពួកគេឈានផុតពីសួនផ្កាកណ្ដាលផ្ទះវាំងទៅរបៀងនៅខាងក្រោយអាគារ។ មុនពេលទៅដល់វាលចម្ការបៃតងស្រស់ពីមុខសន្លឹម នាងត្រូវឆ្លងកាត់ពីលើស្ពានឃោលមួយ ស្អាតឥតខ្ចោះ។

នៅខាងក្រោមជាចរន្តទឹកអូរថ្លាឆ្វង់និងមានដុំសិលាតូចធំរាយគ្នាលាយជាមួយពពួកគ្រួសគ្រប់ពណ៌។

«ថានសួគ៌ទេតើនៀក!»

តម្លៃនៃភាពជាធម្មជាតិកម្រនៃភូមិដ្ឋានមួយនេះ ពិតជាពិសេសអស្ចារ្យជាងអ្វីដែលនាងធ្លាប់បានគិតទុកមកពិតមែន។

នៅលើស្ពាន នារីឈប់ង៉ក់បណ្ដាលឱ្យបុរសសូហ្វ័រដែលបានឆ្លងទៅដល់ម្ខាងអូរទៀតមុនទៅហើយនោះ បែរក្រោយមកសម្លឹងសកម្មភាពស្រស់ស្រី។ ឥតបង្អង់ ធីតាលើកឧបករណ៍ផ្ដិតយកទស្សនីយភាពអស់ទាំងនេះ ទៅតាមអារម្មណ៍ស្ងប់ស្ងែង សឹងភ្លេចថាខ្លួនកំពុងទៅណាមកណា ដើម្បីអ្វី។

«　　អូខេ!ថតរួចហើយ! សុំទោស! មកពីស្អាតពេក!»

នាងនិយាយស្ដីគួរសមតែបុរសនោះក្រៅពីឱនគំនាប់តិចតួចស្នាមញញឹមមួយក៏គ្មានដែរ។

នាងទើបតែដឹងថា មិនអាចរកបន្ទប់មានរឿងហេតុនោះឃើញទេប្រសិនមិនបានគេនេះជូនមក។ នេះជាអ្វីដែលនាងទើបនឹងដឹងក្រោយពេលដើរក្រវេចក្រវៀនតាមគេ កាត់តាមរបៀងផ្ទះ និងស្ពានយោល ឆ្លងចម្ការតែនិងមកដល់សួនតូចៗពីរបីថ្មីទៀត។ នៅសួនទីបួននាងឃើញខ្នងលោកជំទាវពីចំងាយ។ គាត់កំពុងតែឱនធ្វើអ្វីម្យ៉ាងក្បែរផ្លូវប្រឡបនឹងសួនផ្កាចម្រុះពណ៌។

«អ្នកមីងមិនសម្រាកទេ?!»

នាងសួរតិចៗដោយភ្នែកផ្ដោតសម្លឹងជំទាវអភិជនដែលកំពុងគាស់ដាំកូនដើមបុប្ផាតូចៗ។

«គាត់ស្រលាញ់ការងារថែទាំដើមផ្កាណាស់ ឱ្យតែនៅផ្ទះមិនដែលសម្រាកទេ!»

មនុស្សយើងតែងមានចំណង់ចំណូលចិត្តខុសៗគ្នា។ ជំនក់ចិត្តលើអ្វីមួយ អាចធ្វើឱ្យមនុស្សយើងមានសេចក្ដីសុខជាងការសម្ងំគេងហើយកើតទុក្ខព្រួយរីងរៃ។ នេះជាអ្វីដែលនាងកំពុងគិត។

«អ៊ីចឹងបានផ្ទះនេះស្អាតរកចន្លោះទើសគ្មាន!»

នាងវាចាតិចៗបញ្ចប់ប្រធានបទ ហើយបន្ដដើរតាមពីក្រោយបុរសនាំផ្លូវ។ នៅមុខប៉ុន្មានជំហាន នារីអ្នកកាសែតឃើញរទេះជនចំណាស់ ដែលមុននេះធ្លាក់ខ្លួនឈឺ។ ការបាត់បង់មិត្តភក្ដិវ័យជរារបស់ខ្លួនគឺជាការឈឺចាប់មួយ។ អ៊ំសំភិនឱបវិទ្យុស្ដាប់ ដោយមិនរវល់នឹងអ្នកណាទាំងអស់។ នាងក៏មិនចង់រំខានភាពស្ងប់ស្ងាត់របស់គាត់ដែរ ទើបដើរលឿនហួសទៅ។

«ពូឈ្មោះ?»

នាងសួរពីក្រោយធ្វើឱ្យអ្នកនាំផ្លូវភ្ញាក់។ គេនោះបង្អង់គិតទើបសួរបកៈ

«ឈ្មោះខ្ញុំហ្មែន?!»

មានអ្នកណាទៀត? នាងគិតទាំងហាក់ចាប់អារម្មណ៍ធុញទ្រាន់នឹងអាកប្បកិរិយាអាថ៌កំបាំង លាក់ៗនៃអ្នកបើកឡាន។ ស្រីស្អាតមិនមាត់បន្ថែមហាក់ធ្វើឱ្យជននោះដឹងខ្លួន ថានាងអន់ចិត្តចំពោះការបន្លាយពេលរបស់ខ្លួន។ គេនោះឆ្លើយមកវិញបន្ថែមៈ

«ខ្ញុំឈ្មោះធឿន!»

ស្រីស្អាតបន្តដំណើរដោយស្ងប់ស្ងៀមខណៈ សួនថ្មីតូចប្រមាណជា ៤០ម៉ែត្រការ៉េតែចម្រុះដោយបណ្ដាដើមផ្កាចំប៉ីចំប៉ាជំទើរៗគ្រប់ពណ៌រីកធំត្រសុំត្រសាយបែកមែកធាងសាខាបង្ហាញខ្លួន។ កម្រ

ដែលឃើញចំប៉ីមានគ្រប់ពណ៌យ៉ាងនេះ។ ពីមុនបើមិនឃើញចំប៉ីសនិងក្រហម នាងមិនដែលឃើញមានជាតិចំប៉ីបៃតងស្រស់ ត្រួយចេកលឿង និងទឹកក្រូចព្រឿងបែបនេះពិតមែន។ ចំជាម្ចាស់ផ្ទះជាអ្នកជំនាញផ្កាពិតណាស់ ហើយក៏សមឥតទាស់នឹងឈ្មោះថា «វិមានក្រអូប» ដែរ។

ទ្វារឈើធំមួយ មានពណ៌សសឹងស្រដៀងជាមួយនឹងឈើកៅស៊ូដ៏ពេញនិយមនាពេលបច្ចុប្បន្ន តែមើលទៅក្រាស់និងធ្ងន់។ ដ្បិតតែវាមិនមានឆ្លាក់ក្បាច់អ្វីដូចរចនាបទផ្ទះខាងមុខ តែទីនេះពិតជាបង្កប់នូវគុណតម្លៃប្រណីតមួយបែបផ្សេង។

នេះឯងបន្ទប់កើតហេតុ?

ក្រែងថាជាបន្ទប់ធំសម្រាប់ទទួលភ្ញៀវពន្លឺ ចុះហេតុអ្វីបានជានៅជ្រុងជ្រោយកាត់សួនក្រវិចក្រវៀនដល់ទៅមួយគំនរគរដឹក? បានន័យថាកាលពីយប់មួយនោះ ភ្ញៀវពិសេសទាំងអស់សុទ្ធតែត្រូវបានគេនាំថ្មើរជើងមកជុំគ្នាអបអរឆ្នាំថ្មីនៅទីនេះ?

«ដល់ហើយទាន!»

បុរសនិយាយតិចៗប្រាប់នាង ហើយឈប់ដំណើរឱ្យទុកនាងបោះជំហានទៅមុខ។ ទីនេះប្រមាណជា ៦ទៅ ៧ម៉ែត្រទៀតទើបទៅដល់ទ្វារបន្ទប់ធំ។ ដ្បិតតែទ្វារឈើនោះគេប្រាប់មកជាមុនថាបានបើកសោរួចមែនតែនាងមើលទៅធ្ងន់កណ្ដុក សមថារចនាឡើងអំពីសន្លឹកឈើប្រណីតក្រាស់ឃ្មឹកមួយផ្ទាំងធំ យ៉ាងកម្រក។ មនុស្សនៅទីនេះបានបំផ្លាញព្រៃឈើកម្រិតណាទៅទម្រាំកសាងបាននូវវិមានក្រអូបដ៏ស្វាត់កំបាំងមួយនេះ?

«អត់មានអ្នកណាទេ?!»

នាងបោះសំណួរ ហាក់ចង់បញ្ជាក់ថា មិនមានអ្នកនៅយាមកាមថៃទាំទីនេះទេឬអ្វី គ្រាន់តែនាងសួរខ្លីៗ។

«បាទ!អត់ទេ!»

ធឿនឆ្លើយទាំងឱនលំទាន។ នាងសម្លឹងកាយវិការបុរសនេះ ក៏ដឹងថាគេមានសភាពប្រុងប្រយ័ត្នជានិច្ចរាល់ពេលឆ្លើយសំណួររបស់ខ្លួនម្ល៉េះហើយនារីអ្នកកាសែតនិយាយបង្គាប់៖

«បើសោបើករួចហើយ ពូទៅធ្វើការពូវិញចុះ!!»

មនុស្សប្រុសទីទើរ ជាហេតុធ្វើឱ្យនាងធ្វើមុខស្មើសម្លឹងគាត់បង្ហាញពេញទំហឹងថានាងមិនពេញចិត្តប៉ុន្មានឡើយ។

នាងពោលបញ្ជាក់សារជាថ្មី៖

«ខ្ញុំចូលម្នាក់ឯងបានហើយ!»

ជននេះងើបមុខសម្លឹងនាងជាមួយកែវភ្នែករេចុះឡើង រិះគិត។ ទោះនាងធ្វើហី តែធីតាចាប់អារម្មណ៍ដឹងថាបុរសអ្នកបើកបរបានសម្លឹងនាងពីលើដល់ដល់ក្រោម។ លុះឃើញថានាងមកដៃទទេ ទើបគេទំនងជាស្ងប់ចិត្តវិញ ។

«បាទទាន!»

មុនទៅគេឆ្លៀតងាកមកផ្តាំ៖

«ពេលអ្នកនាងចប់កិច្ចការ ប្រាប់ខ្ញុំផងខ្ញុំនឹងអាលបិទទ្វារវិញទាន!»

«ឱ្យសោមកខ្ញុំ!»

នាងនិយាយយ៉ាងរហ័សហើយហុចដៃទៅផង។

«សោជូនទៅលោកជំទាវវិញហើយទាន!»

គេឆ្លើយមកវិញរហ័សដូចគ្នាជាហេតុបណ្តាលឱ្យនារីត្រូវចងចិញ្ចើមឆ្ងល់ជាមួយនឹងសំណួរជាច្រើនលេចឡើងក្នុងចិត្ត

«ប្រយត្ន័ម៉េះ?»។

គេនោះស្រាប់តែប្រញាប់ដកថយក្រោយបានឆ្លើយនូវចម្លើយចុងក្រោយនេះរួចរាល់។

«អញ្ជើញតាមសម្រួល!»

បុរសចាកចេញទៅវិញយ៉ាងប្រញិបប្រញាប់ ក្រោមកែវភ្នែកមិនស្រួលចិត្តរបស់ធីតាដែលបន្តតាមសម្លឹងមើលដំណើរគេនោះរហូតបាំងបាត់ក្រោយស្រមោលរុក្ខាធំៗ ទើបនាងបែរមករកទ្វារជាគោលដៅវិញម្តង។

**ជំពូកទី១០**

**បន្ទប់កើតហេតុ**

ក្រាកៗ....

ទោះបីថាទ្វារដ៏ធ្ងន់និងធំនេះ បន្លឺសំឡេងខ្លះមែនតែធីតារុញវារបើកទៅក្នុងយ៉ាងងាយស្រួល។ ខុសពីការគិតមុននេះ ដែលថាខ្លួនត្រូវរាវរកកុងតាក់ភ្លើង ភ្នែកនាងត្រូវភាំងភាន់នឹងសម្រស់ល្អត្រកាលនៃទីនេះ។ គ្រប់យ៉ាងមិនបានងងឹតទេ ផ្ទុយទៅវិញ ទីនេះសឹងថាភ្លឺទែង និងបៃតងស្រស់ជាងបន្ទប់រំចេករបស់នាងផង។

នៅខាងឆ្វេងដៃ ជញ្ជាំងទាំងស្រុងត្រូវបានធ្វើឡើងពីផ្ទៃកញ្ចក់សថ្លា ហើយពីក្រោយកញ្ចក់ ពណ៌បៃតងស្រស់នៃសំណុំមែកឈើធំតូច បានបង្អួតទីនេះស្មើនឹងវិចិត្រសាលកម្រុក។ ពន្លឺនៃព្រះអាទិត្យពេលរសៀលជះរស្មីពេញទំហឹងបំភ្លឺផ្ទៃបន្ទប់ទាំងមូលឱ្យក្លាយជាទិដ្ឋភាពប្រណីតជាប់ចិត្តមិនអាចមិនជញ្ជក់មាត់សរសើរឡើយ។

នារីវេភ្នែកមករកជញ្ជាំងខាងស្តាំ។ ទោះបីទីនេះមិនមែនជាផ្ទាំងកញ្ចក់បង្អួតសួនផ្កាចំប៉ានៅខាងក្រៅ តែក៏ជាទីតំកល់មកនូវផ្ទាំងគំនូរ ពិសេសៗ ល្មមបញ្ជាក់ហេតុផលស្រេចថាហេតុអ្វីជំទាវវត្តីទុកទីនេះជាកន្លែងពិបាកចេញចូល?